**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**
**ប្រធានរដ្ឋសភា និងលោកជំទាវ**

**សម្តេចអគ្គមហាពញាចក្រី និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតកម្ពុជាទាំងអស់ ដែលកំពុងបំពេញបេសកកម្មការទូតនៅបរទេស ខ្ញុំបាទ និងភរិយា សូមសំដែងនូវមនោសញ្ចេតនាគោរពជូនពរ បវរសួស្តី សិរីមង្គល វិបុលសុខ ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី** និង**លោកជំទាវ** សូមមានសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ ថាមពលខ្លាំងក្លា ប្រាជ្ញាវាងវៃ និងទទួលបានជោគជ័យធំធេងថ្មីៗ ថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម និងកិច្ចខិតខំប្រឹងប្រែងពុំចេះនឿយហត់ ទាំងកម្លាំង កាយចិត្ត និងប្រាជ្ញារបស់ **សម្តេចអគ្គមហាពញាចក្រី** ក្នុងការដឹកនាំប្រទេសជាតិ ជាពិសេស ស្ថាប័នរដ្ឋសភា ឱ្យទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ជាបន្តបន្ទាប់ ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ ឯកភាពជាតិ នីតិរដ្ឋ អធិបតេយ្យភាព បូរណភាពទឹកដី និងនាំមកនូវមោទនភាពជាតិនៅលើឆាកអន្តរជាតិ ដើម្បីជាតិមាតុភូមិ ជាទីស្នេហានៃយើង។

សាជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក និងទេវតារក្សាព្រះរាជាណាចក្រកម្ពុជា សូមតាមជួយបីបាច់ថែរក្សា **សម្តេចអគ្គមហាពញាចក្រី** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី ជាទីស្រឡាញ់ ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាពញាចក្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ និងភរិយា។

ថ្ងៃ ពុធ ៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

**ប្រាក់ សុខុន** **ខេង សំវ៉ាដា**


អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh